ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ១៤២/១០-៨ ស្ដារ ស្កតវែរ**

**កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ : ថ្ងៃទី២៥ ខែមករា ឆ្នាំ២០១១**

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក: **អ៊ឹង សុទ្ធី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត: **អន ណន**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ: **ប៉ែន ប៊ុនឈា**

**ភាគីនៃវិវាទ**

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន ៨ ស្ដារ ស្កតវែរ**

អាសយដ្ឋាន : ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០៧៧ ៧៧៨ ៦១៦ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោកស្រី Susan Lee | នាយិកាក្រុមហ៊ុន |
| ២- លោក នូ ម៉ុន | ប្រធានរដ្ឋបាល |
| ៣- លោក ជាតិ ខេមរា | មន្ត្រីសមាគមរោងចក្រកាត់ដេរកម្ពុជា |
| ៤- លោកស្រី អោ ធារី | ជំនួយការនាយិកា |

២- ភាគីកម្មករនិយោជិត

ឈ្មោះ : - **សម្ព័ន្ធសហជីពចលនាកម្មករ**

- **សហជីពចលនាកម្មករនៃរោងចក្រកាត់ដេរ ៨ ស្ដារ ស្កតវែរ**

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

អាសយដ្ឋាន : ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០៨៩ ៦៤៦ ៤០៧ ទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

១- លោក អ៊ូ សូផាត អនុប្រធានសម្ព័ន្ធសហជីពចលនាកម្មករ

២- លោក ឡុង តែស៊ាន់ មន្ត្រីសម្ព័ន្ធសហជីពចលនាកម្មករ

៣- កញ្ញា សោម សារុំ ប្រធានសហជីពចលនាកម្មករប្រចាំរោងចក្រ

៤- កញ្ញា យុង សុខី អនុប្រធានសហជីពចលនាកម្មករប្រចាំរោងចក្រ

៥- លោកស្រី ណយ រិន លេខាធិការសហជីពចលនាកម្មករប្រចាំរោងចក្រ

៦- លោកស្រី សួស ចាន់ណាក់ លេខាធិការរងសហជីពចលនាកម្មករប្រចាំរោងចក្រ

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៃក្រុមហ៊ុន ៨ ស្តារ ស្ពតវែរ នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរ ចំនួន ១០ ដុល្លារ ក្នុងមួយខែ និងថ្លៃជួលផ្ទះ ១០ ដុល្លារក្នុងមួយខែ រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃក្រុមហ៊ុនបាន ប្តូរទីតាំង មូលហេតុកម្មករនិយោជិតទាមទារលុយនេះ គឺទាមទារតាំងពីនៅទីតាំងរោងចក្រចាស់ម្លេះ តាមរយៈ សហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្ពតវែរ តែមិនបានលទ្ធផលសោះ ទើបបងប្អូនសម្រេចធ្វើការទាមទារ លុយនេះឡើងវិញ (គ្មានឯកសារទេ និយាយមាត់ទទេ)។ ដោយឡែក ភាគីក្រុមហ៊ុនមិនអាចធ្វើការដោះស្រាយ តាមសំណើររបស់បងប្អូនថ្នាក់ដឹកនាំសម្ព័ន្ធសហជីពចលនាកម្មករនៃរោងចក្រ ៨ ស្តារ ស្ពតវែរ បានឡើយ ដោយ សហជីពនេះ កើតក្រោយព្រឹត្តិការណ៍ និងមុននឹងធ្វើការផ្លាស់ប្តូរទីតាំងរោងចក្រមកទីតាំងថ្មីនេះ គឺក្រុមហ៊ុនបាន ជួបប្រទះនឹងបញ្ហាទីតាំងចាស់ត្រូវបានម្ចាស់ទីតាំងមិនជួលបន្ត ហើយក្រុមហ៊ុនបានធ្វើការដោះស្រាយរួចរាល់ហើយ ជាមួយតំណាង ដែលមានស្រាប់នៅទីតាំងចាស់ (កិច្ចព្រមព្រៀងភ្ជាប់មកជាមួយ)។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុម ប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៣ កប/ប្រក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ (អាណត្តិទី៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១១៣៥ កប/អក/វក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** : ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** : ថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ (វេលាម៉ោង ១៤:០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី:**

នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ នាយកដ្ឋានវិវាទការងារបានទទួលបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ៨ ស្តារ ស្ពតវែរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០ ស្តីពីការទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរ និងថ្លៃជួលផ្ទះជូនកម្មករនិយោជិត ចាប់តាំងពីក្រុមហ៊ុនបានប្តូរទីតាំង។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារបានចាត់តាំងមន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងាររួមនេះ និងផ្សះផ្សានៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នាចំនួន១ចំណុច លើការទាមទារចំនួន១ចំណុច។ ចំណុចមិនសះជានេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជានេះ នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ វេលាម៉ោង ០២: ០០ នាទី រសៀល ) ។

ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកបន្ថែមនូវព័ត៌មានផ្សេងៗ ដែលទាក់ទងទៅនឹងវិវាទនេះ និងបានព្យាយាមធ្វើការផ្សះផ្សាលើករណីមិនសះជានេះជាបន្តទៀត ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម:

## ភស្តុតាង

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- សេចក្តីសង្ខេបនៃរោងចក្រ ៨ ស្តារ ស្ពតវែរ ។

២- លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាលេខ ១៧៨០/១០ គវក ចុះថ្ងៃទិ២៥ ខែសីហា ឆ្នាំ២០១០ ជម្រាបមកលោកប្រធានក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ស្តីពីសំណើសុំប្តូរទីតាំងរបស់ក្រុមហ៊ុន។

៣- លិខិតស្នើសុំរបស់តំណាងសហជីពសេរីប្រចាំរោងចក្រ ៨ ស្តារ ស្តតវែរ ស្តីពីការសុំពេលប្តូររោងចក្រ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ។

៤- កំណត់ហេតុនៃដំណោះស្រាយលើបញ្ហាប្តូរទីតាំងរោងចក្រ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ។

៥- បញ្ជីរាយនាមឈ្មោះអ្នកចូលរួមប្រជុំពីការផ្លាស់ប្តូរទីតាំងក្រុមហ៊ុន ។

៦- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ១១៧១ កប/អក/វក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០៩ ជំរាបមកលោកប្រធានសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ៨ ស្តារ ស្តតវែរ ស្តីពីការស្នើសុំទទួលស្គាល់ថ្នាក់ដឹកនាំសហជីពថ្មី អាណត្តិទី២។

៧- លិខិតរបស់សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៤៧/០៩ សសកពក គោរពជូនលោកនាយកក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ស្តីពីការជូនដំណឹងអំពីថ្នាក់ដឹកនាំសហជីព ថ្មី អាណត្តិទី២ ។

៨- លិខិតរបស់នាយកដ្ឋានវិវាទការងារលេខ ១២៧៥ កប/អក/វក ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៨ ជំរាបមកលោកស្រីនាយិកាក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិក អាណត្តិទី២។

៩- កំណត់ហេតុស្តីពីការបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកប្រចាំក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

១០- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពកម្មករនិយោជិតរោងចក្រ ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៧ ។

១១- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពសេរីកម្មករនៃរោងចក្រ ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០០៨ ។

១២- អនុសញ្ញារួមរវាងនិយោជក និងសហជីពមូលដ្ឋានប្រចាំក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ ។

១៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៧ ។

១៤- ប័ណ្ណប៉ាតង់ ឆ្នាំ២០០៩ ក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៩ ។

១៥- វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ក្រុមហ៊ុន ៨ ស្តារ ស្តតវែរ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ ២០០៧ ។

១៦- ពាក្យសុំចូលបំរើការងារក្នុងក្រុមហ៊ុន ៨ ស្តារ ស្តតវែរ របស់ឈ្មោះ គង់ សុផុន ។

១៧- កិច្ចសន្យាការងាររបស់ឈ្មោះ គង់ សុផុន ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៦ ។

THE ARBITRATION COUNCIL

១៨- វិញ្ញាបនប័ត្រពិនិត្យកាយសម្បទាឈ្មោះ គង់ សុផុន ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦ ។

១៩- ពាក្យសុំចូលបំរើការងារក្នុងក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ របស់ឈ្មោះ ធីន គីមហាន ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦។

២០- កិច្ចសន្យាការងាររបស់ឈ្មោះ ធីន គីមហាន ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

២១- វិញ្ញាបនប័ត្រពិនិត្យកាយសម្បទាឈ្មោះ ធីន គីមហាន ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦ ។

២២- ពាក្យសុំចូលបំរើការងារក្នុងក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ របស់ឈ្មោះ ជឿន ស្រីទូច ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៦។

២៣- កិច្ចសន្យាការងាររបស់ឈ្មោះ ជឿន ស្រីទូច ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៦ ។

២៤- វិញ្ញាបនប័ត្រពិនិត្យកាយសម្បទាឈ្មោះ ជឿន ស្រីទូច ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦ ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :**

១- លិខិតរបស់សម្ព័ន្ធសហជីពចលនាកម្មករលេខ ០៣៥/០១០ សសចក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ គោរពជូនលោកស្រីនាយិកាក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ ស្តីពីការជួបពិភាក្សា ។

២- វិញ្ញាបនប័ត្រចុះបញ្ជិកាសហជីពចលនាកម្មករ នៃរោងចក្រ ៨ ស្តារ ស្កតវ៉ែរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ ។

៣- កំណត់ហេតុផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ លេខ ១១៣៥ កប/អក/វក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ៨ ស្តារ ស្កតវ៉ែរ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការលេខ ៧៥៨ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០១០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧៥៩ កប/អក/វក/លកអ. ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០។

THE ARBITRATION COUNCIL

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- ក្រុមហ៊ុន ៨ ស្តារ ស្តតវ៉េរ បានចាប់បើកដំណើរការនៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៦ ដែលមានទីតាំងចាស់នៅភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ សព្វថ្ងៃនេះ ក្រុមហ៊ុនបានប្តូរមកនៅទីតាំងថ្មី នៅភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ដែលមានជួលកម្មករនិយោជិតចំនួនប្រមាណ ១ ១០០ នាក់។
- នៅក្នុងក្រុមហ៊ុនមានសហជីពចំនួន ២ គឺសហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ៨ ស្តារ ស្តតវ៉េរ និងសហជីពចលនាកម្មកររោងចក្រកាត់ដេរ ៨ ស្តារ ស្តតវ៉េរ។ សហជីពចលនាកម្មកររោងចក្រកាត់ដេរ ៨ ស្តារ ស្តតវ៉េរ ជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ និងមានសមាជិកប្រមាណ ៣០០ នាក់។
- នៅក្នុងក្រុមហ៊ុននេះ មិនមានសហជីពណា មានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទ : ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ៨ ស្តារ ស្តតវ៉េរ នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារក្នុងមួយខែ និងថ្លៃជួលផ្ទះចំនួន ១០ ដុល្លារ រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃក្រុមហ៊ុនបានប្តូរទីតាំង**

- ភាគីកម្មករនិយោជិតបញ្ជាក់ថា ពួកគាត់ទាមទារថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនប្តូរទីតាំង។ មូលហេតុដែលគាត់ធ្វើការទាមទារនេះ ពីព្រោះពួកគាត់យល់ថា នៅពេលដែលក្រុមហ៊ុនផ្លាស់ប្តូរទីតាំង ពួកគាត់ត្រូវទទួលបានអត្ថប្រយោជន៍មួយចំនួនពីភាគីនិយោជក។ ភាគីកម្មករនិយោជិតលើកឡើងបន្ថែមថា បើពួកគាត់ទាមទារនូវចំនួនទឹកប្រាក់លើសពីនេះ ក៏និយោជកមិនអាចផ្តល់ជូនបានដែរ ហើយគោលបំណងដែលកម្មករនិយោជិតទាមទារសម្រាប់រយៈពេល ១២ខែនេះ គឺដើម្បីទុកឱកាសដល់និយោជកក្នុងការពិចារណាផ្តល់ជូនតាមការទាមទារនេះ ឬផ្តល់ជូនទាបជាងការទាមទារនេះក៏បាន។
- ភាគីកម្មករនិយោជិតបានលើកឡើងនូវមូលហេតុថា កម្មករនិយោជិតភាគច្រើន នៅតែស្នាក់នៅក្បែរទីតាំងចាស់ដដែល ព្រោះនៅទីតាំងថ្មី ផ្ទះជួលមានតម្លៃថ្លៃជាងនៅក្បែរទីតាំងចាស់ ហើយម្ហូបអាហារ

ក៏មានតម្លៃថ្លៃជាងនៅទីតាំងចាស់ដែរ។ លើសពីនេះ រោងចក្រថ្មីមានទីតាំងឆ្ងាយ ពីរោងចក្រចាស់ប្រហែល ៣ ទៅ ៤ គីឡូម៉ែត្រ។ ហេតុនេះ កម្មករនិយោជិតត្រូវចំណាយប្រាក់ច្រើនជាងមុន ចំពោះសោហ៊ុយធ្វើដំណើរពីទីតាំងចាស់ទៅទីតាំងថ្មី។ ភាគីនិយោជកបានជំទាស់នឹងការលើកឡើងនេះ ដោយបញ្ជាក់ថា ចម្ងាយពីទីតាំងចាស់មកទីតាំងថ្មីមិនឆ្ងាយប៉ុន្មានទេ គឺត្រឹមប្រហែលមួយគីឡូម៉ែត្រប៉ុណ្ណោះ។

- ភាគីសហជីពបានបញ្ជាក់ថា ពួកគាត់ធ្លាប់ជាសមាជិកសហជីពរបស់សហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ៨ ស្តារ ស្តតវែរ មុនពេលដែលក្រុមហ៊ុនផ្លាស់ប្តូរទៅតាំងថ្មី។ សព្វថ្ងៃតំណាងភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ជាលេខាសហជីពចលនាកម្មករនៃរោងចក្រកាត់ដេរ ៨ស្តារ ស្តតវែរ។
- ភាគីនិយោជកបានលើកឡើងថា ក្រុមហ៊ុនបានចាប់ផ្តើមធ្វើការរើក្រុមហ៊ុនពីទីតាំងចាស់ ទៅតាំងថ្មីចាប់ពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១០។ ភាគីនិយោជកបានលើកឡើងថា មូលហេតុដែលក្រុមហ៊ុនត្រូវធ្វើការផ្លាស់ប្តូរទីតាំងនេះ គឺមកពីក្រុមហ៊ុនជួបប្រទះវិបត្តិសេដ្ឋកិច្ច ហើយម្ចាស់ក្រុមហ៊ុនត្រូវសម្រេចចិត្តលក់រោងចក្រទៅឱ្យម្ចាស់ថ្មី ឯម្ចាស់អគារក៏ចាប់ផ្តើមផ្តាច់កិច្ចសន្យាជួល។ ហេតុនេះ ទើបក្រុមហ៊ុនសម្រេចចិត្តប្តូរទីតាំង នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១០។
- ផ្អែកតាមឯកសាររបស់ភាគីនិយោជក ដែលដាក់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០១១ ក្នុងអំឡុងពេលជូនដំណឹងអំពីការផ្លាស់ប្តូររោងចក្រនោះ សហជីពសេរីកម្មករនៃរោងចក្រកាត់ដេរ ៨ស្តារ ស្តតវែរ បានដាក់លិខិតស្នើសុំនូវសោហ៊ុយធ្វើដំណើរ និងថ្លៃជួលផ្ទះ តែរោងចក្រមិនបានឯកភាពទៅលើសំណើររបស់សហជីពសេរីនេះទេ។
- ផ្អែកតាមកំណត់ហេតុនៃដំណោះស្រាយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ តំណាងសហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្តតវែរ បានឯកភាពគ្នានៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ថាក្រុមហ៊ុនអនុញ្ញាតឱ្យក្រុមនីមួយៗឈប់សម្រាកមួយថ្ងៃ (ដោយគិតប្រាក់ឈ្នួលពេញ និងប្រាក់រង្វាន់ផ្សេងៗនៅដដែល) មុនថ្ងៃដែលក្រុមនីមួយៗរើទៅទីតាំងថ្មី ប៉ុន្តែក្រុមហ៊ុនមិនអាចធ្វើទៅតាមការស្នើសុំ ដោយឱ្យថ្លៃជួលផ្ទះ និងសោហ៊ុយធ្វើដំណើរទៅតាមការស្នើសុំរបស់តំណាងសហជីពបានទេ។ ក្រុមហ៊ុននឹងមិនកាត់ប្រាក់រង្វាន់ពិសេសចំនួន ៧ ដុល្លារអាមេរិក ក្រៅពីប្រាក់រង្វាន់ធ្វើការទៀងទាត់របស់ច្បាប់ ក្នុងករណីកម្មករកម្មាការិនីស្ទះចរាចរណ៍ម្តងម្កាល។
- ភាគីកម្មករនិយោជិតនៅក្នុងសំណុំរឿងនេះ ទទួលស្គាល់ថា នៅពេលដែលសហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្តត វែរ មានការព្រមព្រៀងខាងលើ ជាមួយនឹងក្រុមហ៊ុន សហជីពនេះ គឺជាតំណាងស្របច្បាប់របស់ពួកគាត់ ព្រោះគាត់ជាសមាជិកសហជីពនេះ នៅពេលនោះ។

- ភាគីសហជីពបានលើកឡើងថា ពួកគាត់ដែលធ្លាប់ជាសមាជិកសហជីពសេរី ដែលបានមានកិច្ចព្រមព្រៀងខាងលើនេះ មិនដែលធ្លាប់បានដឹងអំពីអត្ថន័យនៃការព្រមព្រៀងនេះទេ រហូតដល់ក្រោយពេលប្តូរមកទីតាំងថ្មីហើយ ទើបសហជីពសេរីកម្មករប្រចាំរោងចក្រកាត់ដេរ ៨ ស្តារ ស្ពតវែរ ប្រាប់ពួកគាត់អំពីបញ្ហានេះ។ នៅមុនពេលក្រុមហ៊ុនប្តូរមកទីតាំងថ្មី ពួកគាត់ធ្លាប់បានទៅសួរតំណាងសហជីពរបស់គាត់(សហជីពសេរីកម្មករ) អំពីអត្ថប្រយោជន៍នានា ដែលគាត់អាចនឹងទទួលបានពីការដែលក្រុមហ៊ុនប្តូរទីតាំង។ សហជីពសេរីកម្មករបានប្រាប់ពួកគាត់ថា ភាគីនិយោជកមិនឱ្យអត្ថប្រយោជន៍អ្វីទេ ប៉ុន្តែបានបញ្ជាក់ថា ចាំក្រុមហ៊ុនប្តូរទៅទីតាំងថ្មីសិន ចាំពិភាក្សាពីបញ្ហានេះម្តងទៀត។
- សហជីពសេរីកម្មករមិនបានផ្សព្វផ្សាយព័ត៌មានអំពីអ្វី ដែលខ្លួនបានប្រាប់ទាក់ទងនឹងការព្រមព្រៀងនេះ ទៅកម្មករនិយោជិតដែលជាសមាជិកទាំងអស់នោះទេ។
- ភាគីនិយោជកបានធ្វើការជំទាស់នឹងការលើកឡើងរបស់ភាគីកម្មករនិយោជិត ដោយបញ្ជាក់ថាក្រុមហ៊ុនបានបិទកំណត់ហេតុនៃដំណោះស្រាយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ នៅឯរោងចក្រចាស់។ លើសពីនេះទៅទៀត កម្មករនិយោជិតទាំងអស់ រួមទាំងកម្មករនិយោជិតនៅក្នុងបណ្តឹងក៏បានដឹងពីបញ្ហានេះរួចហើយ ព្រោះពួកគាត់ក៏បានឈប់សម្រាកមួយថ្ងៃ ដោយទទួលបានប្រាក់ឈ្នួលពេញ និងប្រាក់រង្វាន់ផ្សេងៗនៅដដែល មុនថ្ងៃដែលក្រុមនីមួយៗរើទៅទីតាំងថ្មី។ ភាគីនិយោជកបានសន្និដ្ឋានថា ភាគីកម្មករនិយោជិតបានដឹងពីបញ្ហានេះរួចទៅហើយ តាមរយៈការឈប់សម្រាកនេះជំនួសឱ្យការមិនផ្តល់ជូនតាមការទាមទាររបស់តំណាងពួកគាត់។ ភាគីកម្មករនិយោជិតមិនឆ្លើយតបនឹងការលើកឡើងរបស់ក្រុមហ៊ុននេះទេ។
- ភាគីនិយោជកនៅតែប្រកាន់ជំហរដដែល គឺមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតទេ។

## ហេតុផលនៃសេចក្តីសម្រេចៈ

**ចំណុចវិវាទ : ភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ៨ ស្តារ ស្ពតវែរ នៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារ ក្នុងមួយខែ និងថ្លៃជួលផ្ទះចំនួន ១០ ដុល្លារ រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃក្រុមហ៊ុនបានប្តូរទីតាំង**

ភាគីសហជីពនៅក្នុងសំណុំរឿងបានលើកឡើងថា កម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្របានផ្តិតមេដៃផ្ទេរសិទ្ធិឱ្យសហជីពនេះតំណាងពួកគាត់នៅក្នុងការទាមទារនេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យសហជីពដាក់ជូននូវភស្តុតាងអំពីអ្នក ដែលផ្តល់សិទ្ធិឱ្យពួកគាត់តំណាងនៅក្នុងសំណុំរឿងនេះ។ ភាគីកម្មករនិយោជិតបានដាក់ភស្តុតាងនេះហួសថ្ងៃកំណត់ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការ

ពិចារណាថា តើភាគីសហជីពនៅក្នុងសំណុំរឿងនេះអាចមានសិទ្ធិតំណាងស្របច្បាប់ឱ្យកម្មករនិយោជិតទាំងអស់ក្រៅពីសមាជិកសហជីពរបស់ខ្លួននៅក្នុងរោងចក្រដែរ ឬទេ?

ប្រការ១៩ នៃប្រកាស០៩៩ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មាត្រានេះមានន័យថា អ្នកដែលជាភាគីវិវាទនៃសំណុំរឿងអាចមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវី ដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបង្គាប់ឱ្យសហជីពដាក់ជូននូវភស្តុតាងអំពីអ្នក ដែលផ្តល់សិទ្ធិឱ្យពួកគាត់តំណាងនៅក្នុងសំណុំរឿងនេះ។ ភាគីកម្មករនិយោជិតបានដាក់ភស្តុតាងនេះហួសថ្ងៃកំណត់មកក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើភស្តុតាង ដែលភាគីសហជីពដាក់មកក្រុមប្រឹក្សាអាជ្ញាកណ្តាលហួសថ្ងៃកំណត់នោះទេ។

ផ្អែកតាមប្រការខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីសហជីពខកខានក្នុងការបង្ហាញថាគាត់ជាតំណាងស្របច្បាប់របស់កម្មករនិយោជិតទាំងអស់នៃរោងចក្រនៅក្នុងការទាមទារចំណុចនេះ។ ហេតុនេះនៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាតែចំពោះសហជីព ដែលជាដើមបណ្តឹង និង សមាជិករបស់សហជីពនេះតែប៉ុណ្ណោះ។

ក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះចំនួន ១០ ដុល្លារអាមេរិក ក្នុងមួយខែ សម្រាប់រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនប្តូរទីតាំង។ ប៉ុន្តែ ក្រុមហ៊ុនមិនអាចផ្តល់ជូនតាមការទាមទារនេះទេ ដោយលើកមូលហេតុថាក្រុមហ៊ុនជួបប្រទះវិបត្តិសេដ្ឋកិច្ច នាំឱ្យម្ចាស់ក្រុមហ៊ុនត្រូវសម្រេចចិត្តលក់រោងចក្រទៅឱ្យម្ចាស់ថ្មី ហើយម្ចាស់អគារក៏ចាប់ផ្តើមផ្តាច់កិច្ចសន្យាជួល។ ហេតុនេះ ទើបក្រុមហ៊ុនសម្រេចចិត្តប្តូរទីតាំង នៅក្នុងអំឡុងខែកក្កដា ឆ្នាំ២០១០ ពីទីតាំងចាស់នៅភូមិឫស្សី សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មកនៅទីតាំងថ្មី នៅភូមដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើក្រុមហ៊ុនមានសិទ្ធិក្នុងការតម្រូវឱ្យកម្មករនិយោជិត ទៅធ្វើការនៅទីតាំងរោងចក្រថ្មីដែរ ឬទេ? តើកម្មករនិយោជិតមានសិទ្ធិទទួលបានថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់រយៈពេល

១២ខែ ពីក្រុមហ៊ុន គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនប្តូរទីតាំងដែរ ឬទេ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានពិនិត្យឃើញថា ច្បាប់ស្តីពីការងារមិនបានចែងឱ្យបានច្បាស់លាស់ពាក់ព័ន្ធនឹងការផ្លាស់ប្តូរទីតាំងរបស់រោងចក្រ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលយកជាមូលដ្ឋានក្នុងការបកស្រាយ និងពិចារណាទេ។ ប៉ុន្តែ មាត្រា ២ នៃច្បាប់ស្តីពីការងារ ចែងថា " *........នឹងទុកជានិយោជកដែលបង្កើតសហគ្រាសតាមន័យនៃច្បាប់នេះ លុះត្រាតែបុគ្គលទាំងនោះមានប្រើកម្មករនិយោជិតម្នាក់ ឬច្រើននាក់ ទោះមិនបានជាប់លាប់ក៏ដោយ។ សហគ្រាស... .......... ។ល។ ក្រោមការគ្រប់គ្រង និងដឹកនាំនៃនិយោជក* "។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រា ២ នេះថា ភាគីនិយោជកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងក្រុមហ៊ុន ដរាបណាការងារគ្រប់គ្រង និងដឹកនាំនោះ ធ្វើឡើងទៅតាមច្បាប់ និងសមហេតុផល ដូចជានៅក្នុងសំណុំរឿងលេខ ១៧/០៣ និង ១៨/០៣-ហូ ហ៊ីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយថា និយោជកមានសិទ្ធិក្នុងការផ្លាស់កម្មករនិយោជិតពីកន្លែងមួយ ទៅកន្លែងមួយ ដោយត្រូវគោរពនូវលក្ខខណ្ឌ ៤ ដូចតទៅ :

១- មិនមានប៉ះពាល់ដល់ការកាត់បន្ថយប្រាក់ឈ្នួល

២- ការផ្លាស់ប្តូរទីកន្លែងការងារទៅឆ្ងាយពីកន្លែងដើម

៣- ការផ្លាស់ប្តូរពេលវេលាធ្វើការពីវេនថ្ងៃទៅយប់ ឬពីយប់ទៅថ្ងៃ

៤- មិនប៉ះពាល់ដល់ជំនាញវិជ្ជាជីវៈសំខាន់ៗ

នៅក្នុងសំណុំរឿងលេខ ១៧/០៣ និង ១៨/០៣-ហូ ហ៊ីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបញ្ជាក់ថា "*ក្នុងការធ្វើសេចក្តីសំរេចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានលូកដៃរំខានដល់សិទ្ធិគ្រប់គ្រង និងចាត់ចែងសកម្មភាពអាជីវកម្ម ឬធុរៈកិច្ចទូទៅរបស់ក្រុមហ៊ុនឡើយ ក្នុងការចាត់ចែងការផ្លាស់ប្តូរការងាររបស់កម្មករនិយោជិត ក្នុងក្រុមហ៊ុន ប្រសិនជាមិនមានប៉ះពាល់ដល់***ការកាត់បន្ថយប្រាក់ឈ្នួល ការផ្លាស់ប្តូរទីកន្លែងការងារ ទៅឆ្ងាយពីកន្លែងដើម ការផ្លាស់ប្តូរពេលវេលាធ្វើការពីវេនថ្ងៃទៅយប់ ឬពីយប់ទៅថ្ងៃ មិនប៉ះពាល់ដល់ជំនាញវិជ្ជាជីវៈសំខាន់ៗ** *ពុំនោះទេត្រូវបានចាត់ទុកថា ជាការបំពានលើកិច្ចសន្យាការងារ ដែលតំរូវឱ្យគោរពទៅតាមនីតិវិធីនៃការបញ្ចប់កិច្ចសន្យាការងារ។ ប្រសិនជាការផ្លាស់ប្តូរការងារនេះ ប្រព្រឹត្តទៅដោយមិន***មានកាត់បន្ថយប្រាក់ឈ្នួល មិនប៉ះពាល់ពេលវេលានិងទីកន្លែងធ្វើការ ហើយមានការកែប្រែទៅលើជំនាញនៃវិជ្ជាជីវៈដែលមានលក្ខណៈសាមញ្ញ និយោជកអាចធ្វើបាន** "។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតមិនបានលើកឡើងអំពីការប៉ះពាល់ទៅលើប្រាក់ឈ្នួលជំនាញ និងវេនការងាររបស់ពួកគាត់ ចេញពីការប្តូរទីតាំងនេះទេ។ ប៉ុន្តែ ភាគីកម្មករនិយោជិតបានលើកឡើងថា ចម្ងាយ

ទៅទីតាំងថ្មីពីកន្លែងស្នាក់នៅរបស់គាត់មានប្រហែលពី ៣ ទៅ ៤ គីឡូម៉ែត្រ (ទីតាំងថ្មី និងទីតាំងចាស់ស្ថិតនៅក្នុងសង្កាត់តែមួយ) ហើយតម្លៃនៃការរស់នៅ និងម្ហូបអាហារក្បែរទីតាំងថ្មីមានតម្លៃថ្លៃជាងនៅក្បែរទីតាំងចាស់។

ផ្អែកតាមកំណត់ហេតុនៃដំណោះស្រាយ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១០ តំណាងសហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្តតវែរ បានឯកភាពគ្នា នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១០ ថា ក្រុមហ៊ុនបានអនុញ្ញាតឱ្យក្រុមនីមួយៗឈប់សម្រាកមួយថ្ងៃ (ដោយគិតប្រាក់ឈ្នួលពេញ និងប្រាក់រង្វាន់ផ្សេងៗនៅដដែល) មុនថ្ងៃដែលក្រុមនីមួយៗរើទៅទីតាំងថ្មី ប៉ុន្តែក្រុមហ៊ុនមិនអាចធ្វើទៅតាមការស្នើសុំ ដោយឱ្យថ្លៃជួលផ្ទះ និងសោហ៊ុយធ្វើដំណើរ ទៅតាមការស្នើសុំរបស់តំណាងសហជីពបានទេ។ ក្រុមហ៊ុននឹងមិនកាត់ប្រាក់រង្វាន់ពិសេស ចំនួន ៧ ដុល្លារអាមេរិក ក្រៅពីប្រាក់រង្វាន់ធ្វើការទៀងទាត់របស់ច្បាប់ ក្នុងករណីកម្មករ កម្មការិនី ស្លុះចរាចរណ៍ម្តងម្កាល។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាបន្តថា តើកិច្ចព្រមព្រៀងនេះ ស្របច្បាប់ និងអាចទទួលយកបានដែរ ឬទេ ចំពោះការប្តូរទីតាំងរបស់ក្រុមហ៊ុន?

មាត្រា ១ នៃក្រឹត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ចែងថា *"កិច្ចសន្យា គឺជាឆន្ទៈ ព្រមព្រៀងរវាងបុគ្គល២នាក់ ឬ ច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទិននឹងខ្លួន។*

*... នីតិបុគ្គលអាចធ្វើកិច្ចសន្យាតាមរយៈបុគ្គល ដែលជាតំណាងរបស់ខ្លួន"*។

មាត្រាខាងលើនេះ មានន័យថា កិច្ចព្រមព្រៀង ឬកិច្ចសន្យាកើតឡើងចេញពីឆន្ទៈរបស់ភាគីនៃកិច្ចព្រមព្រៀង ឬកិច្ចសន្យានោះ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬច្រើនដែលទាក់ទងទៅនឹងពួកគាត់។ កិច្ចព្រមព្រៀង ឬកិច្ចសន្យាក៏អាចត្រូវធ្វើឡើង ដោយនីតិបុគ្គល ដែលជាអ្នកតំណាងរបស់បុគ្គលរបស់ខ្លួនផងដែរ។

មាត្រា២៦៨ នៃច្បាប់ស្តីពីការងារចែងថា *"ដើម្បីឱ្យអង្គការវិជ្ជាជីវៈទទួលបាននូវសិទ្ធិ និងផលប្រយោជន៍ទាំងឡាយ ដែលច្បាប់ការងារនេះទទួលស្គាល់ស្ថាបនិកនៃអង្គការវិជ្ជាជីវៈទាំងនោះ ត្រូវយកលក្ខន្តិកៈ និងបញ្ជីរាយនាមនៃអ្នកទទួលខុសត្រូវក្នុងការដឹកនាំ និងកិច្ចការរដ្ឋបាលទៅតំកល់ទុកនៅក្រសួងទទួលបន្ទុកវិស័យការងារដើម្បីសុំចុះបញ្ជិកា........"*។

ប្រការ៥ នៃប្រកាស៣០៥ កថាខ័ណ្ឌ១ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ចែងថា *"សហជីពទាំងអស់ដែលបានបង្កើតឡើងនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ស្របតាមមាត្រា២៦៨ នៃច្បាប់ស្តីពីការងារ មានសិទ្ធិតំណាងឱ្យផលប្រយោជន៍របស់សមាជិករបស់ខ្លួន តាមលក្ខខណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីការងារ "* ។

ផ្អែកតាមមាត្រា២៦៨ នៃច្បាប់ស្តីពីការងារ និងប្រការ៥ នៃប្រកាស៣០៥ កថាខ័ណ្ឌ១ ខាងលើ សហជីពទាំងអស់ដែលបង្កើតឡើងនៅថ្នាក់សហគ្រាស គ្រឹះស្ថាន ស្របតាមមាត្រា២៦៨ នៃច្បាប់ស្តីពីការងារ មានសិទ្ធិតំណាងឱ្យផលប្រយោជន៍របស់សមាជិករបស់ខ្លួន តាមលក្ខខណ្ឌ ដូចមានចែងក្នុងច្បាប់ស្តីពីការងារ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិតទទួលស្គាល់ថា នៅពេលដែលសហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្តតវែរ មានការព្រមព្រៀងខាងលើ ជាមួយនឹងក្រុមហ៊ុន សហជីពនេះ គឺជាតំណាងស្របច្បាប់

របស់ពួកគាត់ ពីព្រោះគាត់ជាសមាជិកសហជីពនេះ នៅពេលនោះ ។

ផ្អែកតាមមាត្រា១ នៃក្រឹត្យច្បាប់លេខ ៣៨ ខាងលើ សហជីពសេរីកម្មករប្រចាំរោងចក្រ ៨ ស្តារ ស្គតវែរ មានសិទ្ធិតំណាងឱ្យភាគីកម្មករនិយោជិត នៅក្នុងសំណុំរឿងនេះ ក្នុងការព្រមព្រៀងនោះ ជាមួយនិយោជក ពីព្រោះកម្មករនិយោជិតនៅពេលនោះ សហជីពនេះជាតំណាងស្របច្បាប់របស់ពួកគាត់ ។

លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ចម្ងាយ ៣ ទៅ ៤ គីឡូម៉ែត្រ មិនមែនជាចម្ងាយដែលឆ្ងាយពេកទេ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញទៀតថា តាមរយៈកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុនបានព្យាយាមផ្តល់អត្ថប្រយោជន៍មួយចំនួន ដល់កម្មករនិយោជិត នៅពេលផ្លាស់ប្តូរនេះ នូវការឈប់សម្រាកមួយថ្ងៃ (ដោយគិតប្រាក់ឈ្នួលពេញ និងប្រាក់រង្វាន់ផ្សេងៗនៅដដែល) និងប្រាក់រង្វាន់ពិសេស ចំនួន ៧ ដុល្លារអាមេរិក ក្នុងករណីស្ទះចរាចរណ៍ ។ ភាគីកម្មករនិយោជិត មិនបានបង្ហាញភស្តុតាងជាក់លាក់ថា ចំណាយនៅទីតាំងថ្មី ពិតជាថ្លៃជាងនៅទីតាំងចាស់នោះទេ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចព្រមព្រៀងនេះ គឺស្របច្បាប់ និងអាចទទួលយកបាន ។ លើសពីនេះ ភាគីនិយោជកបានបិទកំណត់ហេតុនេះ នៅឯរោងចក្រចាស់ មុនពេលក្រុមហ៊ុនប្តូរទីតាំង ហើយភាគីកម្មករនិយោជិតថែមទាំងបានទទួលយកអត្ថប្រយោជន៍ ដូចដែលបានកំណត់នៅក្នុងកំណត់ហេតុនោះ ពីភាគីនិយោជករួចអស់ទៅហើយដែរ ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីនិយោជកបានប្តូរទីតាំងនេះ ដោយត្រឹមត្រូវ និងសមហេតុផល ។

ប៉ុន្តែ នៅក្នុងករណីនេះ ភាគីកម្មករនិយោជិតទាមទារបន្ថែមទៀត នូវថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់រយៈពេល១២ ខែ គិតចាប់ពីថ្ងៃ ដែលក្រុមហ៊ុនប្តូរទីតាំង ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតធ្វើការទាមទារនូវអត្ថប្រយោជន៍ ដែលមិនចែងនៅក្នុងច្បាប់ស្តីពីការងារ បទប្បញ្ញត្តិការងារផ្សេងទៀត ហើយជាអ្វីដែលពួកគាត់មិនអាចទទួលបាននៅក្នុងកិច្ចព្រមព្រៀង ដែលបានចុះជាមួយនឹងនិយោជក នាំឱ្យវិវាទនេះ ជាវិវាទពីផលប្រយោជន៍ ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាអំពីវិវាទទាក់ទងនឹងផលប្រយោជន៍ ចំពោះករណីដែលភាគីកម្មករនិយោជិតនាំបណ្តឹងមកកាន់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ជាសហជីពដែលមានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតនៅក្នុងរោងចក្រ ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាពជាតំណាងបំផុតរបស់សហជីពនេះ ផ្តល់អំណាចផ្លូវច្បាប់ក្នុងការចរចាបង្កើតអនុសញ្ញារួម ក្នុងក្រុមហ៊ុនមួយ និងសិទ្ធិស្របច្បាប់ ក្នុងការនាំសំណុំរឿងវិវាទ អំពីផលប្រយោជន៍មួយមកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយ ។ ដើម្បីទទួលបានភាពជាតំណាងបំផុតនេះ មាត្រា២៧៧ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា សហជីពត្រូវចុះបញ្ជិកា និងត្រូវបំពេញតាមលក្ខខណ្ឌផ្សេងៗទៀត ដែល

មានចែងក្នុងមាត្រានេះ ។

ម្យ៉ាងទៀត ប្រការ ៤៣ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ បានចែងថា *"សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដែលដោះស្រាយវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍នឹងមកជំនួសអនុសញ្ញារួមសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃដែលសេចក្ដីបង្គាប់នោះចូលជាស្ថាពរ លើកលែងតែភាគីចរចាបង្កើតអនុសញ្ញារួមមួយ ដើម្បីជំនួសសេចក្ដីបង្គាប់នេះ"* ។

ផ្អែកលើប្រការ៤៣ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា បើក្រុមប្រឹក្សាអាជ្ញាកណ្ដាលចេញសេចក្ដីបង្គាប់ ដែលដោះស្រាយវិវាទអំពីផលប្រយោជន៍ វានឹងក្លាយជាអនុសញ្ញារួមរយៈពេលមួយឆ្នាំ។ ជាទូទៅអនុសញ្ញារួមត្រូវបានអនុវត្តចំពោះកម្មករនិយោជិតទាំងអស់នៅក្នុងរោងចក្រ ហើយសិទ្ធិក្នុងការធ្វើកូដកម្មមិនអាចអនុវត្តឡើងសម្រាប់សើរើឡើងវិញនូវអនុសញ្ញារួម នៅពេលដែលអនុសញ្ញារួមនោះ មិនទាន់ផុតកំណត់នោះទេ (សូមមើលសេចក្ដីបង្គាប់របស់អាជ្ញាកណ្ដាលលេខ *១៥២/០៨-វិលសិន ហេតុផលចំណុចវិវាទទី២* និងលេខ *៤៨/០៩-វ៉ូស៊ីង ហេតុផលចំណុចវិវាទទី២* )។

ម្យ៉ាងវិញទៀត ប្រសិនបើសហជីពមួយមិនទាន់មានភាពជាតំណាងបំផុតទេ នាំឱ្យសហជីពនេះ មិនមានសិទ្ធិស្របច្បាប់ក្នុងការធ្វើអនុសញ្ញារួម ក្នុងនាមកម្មករនិយោជិតក្នុងរោងចក្រទាំងមូលបានទេ ( *សូមមើលមាត្រា ៩៦ កថាខ័ណ្ឌទី ២-ខ និងប្រកាសលេខ ៣០៥ ប្រការ ៩ កថាខ័ណ្ឌទី ១*) ។ សិទ្ធិនេះជារបស់សហជីព ដែលបានចុះបញ្ជិកា និងមានសមាជិកច្រើនជាងគេ ហើយបំពេញបានតាមលក្ខណៈវិនិច្ឆ័យឯទៀត ដែលមានចែងក្នុងមាត្រា ២៧៧ នៃច្បាប់ស្ដីពីការងារ ។

តាមអង្គហេតុខាងលើ សហជីពចលនាកម្មករប្រចាំរោងចក្រ ៨ ស្ដារ ស្ពតវ៉ែរ ដែលជាដើមបណ្ដឹងនៅក្នុងសំណុំរឿងនេះ មិនមានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតនោះទេ នៅក្នុងរោងចក្រ ។

ជាទូទៅ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបដិសេធការពិចារណាវិវាទអំពីផលប្រយោជន៍ ប្រសិនបើសហជីពដែលនាំវិវាទការងារនោះ ជាសហជីពដែលមិនមានភាពតំណាងបំផុតនៅក្នុងរោងចក្រ ដោយសារការទាមទារបែបនេះ ធ្វើឱ្យប៉ះពាល់សិទ្ធិរបស់កម្មករនិយោជិតផ្សេងទៀត ព្រោះសេចក្ដីបង្គាប់អាជ្ញាកណ្ដាលនឹងក្លាយជាអនុសញ្ញារួម (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល *លេខ ៨១/០៤-អេវើគ្រីន ហេតុផលចំណុចវិវាទទី៤, លេខ ០៩/០៥-គីនតាយ ហេតុផលចំណុចវិវាទទី២, លេខ ៨៤/០៧-យ៉ុង វ៉ា ២ ហេតុផលចំណុចវិវាទទី១, លេខ ១០៨/០៧-៨ ស្ដារ ស្ពតវ៉ែរ ហេតុផលចំណុចវិវាទទី៣, លេខ ១៣៥/០៧-វិល សិន ហេតុផលចំណុចវិវាទទី១, លេខ ១៤/០៨-ហ្វីកស៊ូ ហេតុផលចំណុចវិវាទទី៣, លេខ ១០១/០៨-ជី ឌី អឹម ហេតុផលចំណុចវិវាទទី៣ និង លេខ ៤២/០៩-វីវើរីចហេតុផលចំណុចវិវាទទី២*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការបកស្រាយ របស់ក្រុមអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងខាងលើដែរ គឺសហជីពចលនាកម្មករប្រចាំរោងចក្រ ៨ ស្ដារ ស្ពតវ៉ែរ មិនទាន់មានលក្ខណៈសម្បត្តិ

គ្រប់គ្រាន់ស្របតាមផ្លូវច្បាប់ ក្នុងការនាំវិវាទអំពីផលប្រយោជន៍មកឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការដោះស្រាយបានទេ ពីព្រោះសហជីពចលនាកម្មករប្រចាំរោងចក្រ ៨ ស្ពារ ស្វេតវែរ មិនទាន់មានវិញ្ញាបនប័ត្របញ្ជាក់ពីភាពជាតំណាងបំផុតនៅឡើយទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិតឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនប្តូរទីតាំង។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាល សម្រេចចេញសេចក្តីបង្គាប់ដូចតទៅ :

## សម្រេច និង បង្គាប់

**ចំណុចវិវាទ:** បដិសេធពិចារណាការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនផ្តល់ថ្លៃសោហ៊ុយធ្វើដំណើរ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ ឬថ្លៃជួលផ្ទះ ចំនួន ១០ ដុល្លារអាមេរិកក្នុងមួយខែ សម្រាប់រយៈពេល ១២ ខែ គិតចាប់ពីថ្ងៃដែលក្រុមហ៊ុនប្តូរទីតាំង។

**ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតាមរយៈលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :**

ឈ្មោះ : **អ៊ុំ សុខឌី**

ហត្ថលេខា: ------------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :**

ឈ្មោះ : **អន ណាន**

ហត្ថលេខា: ------------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល :**

ឈ្មោះ : **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------------

THE ARBITRATION COUNCIL